ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៣  លេខ ០២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច  សង្គមកិច្ច  និងវប្បធម៌

# សកម្មភាព  ការងារ

ECOSOCC

ក
ស
វ



Work Activities

ប្រចាំខែ  កុម្ភៈ  ឆ្នាំ  ២០១០

# មាតិកាអត្ថបទ

## កិច្ចប្រជុំទី១ រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


ល.រ ឈ្មោះអត្ថបទ

១. សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការសុំច្បាប់ឈប់ និងច្បាប់ឈប់សម្រាករបស់មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ........ ១–២

២. សេចក្តីព្រាងច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ........ ៣–៤

៣. សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ........ ៥–៦

៤. ប្រជុំបន្តលើសេចក្តីព្រាងរបាយការណ៍ជាតិលើកទី៤ និងទី៥ ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅប្រទេសកម្ពុជា ........ ៧

៥. ប្រជុំឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពី នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ........ ៨

៦. ប្រជុំបន្តលើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើប ........ ៩

៧. សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ........ ១០–១៧

*សេចក្តីព្រាងអនុក្រឹត្យស្តីពី*

# ការបំពេញបន្ថែមលើអនុក្រឹត្យលេខ ៥២ អនក្រ,បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណរដ្ឋបាល



កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អុន** សមាជិកក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្តម **អ៊ុក គុរី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ ៥២ អនក្រ,បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណរដ្ឋបាល** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

អនុក្រឹត្យលេខ ៥២ អនក្រ,បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណរដ្ឋបាល មានកង្វះខាតលើចំណុចមួយចំនួនដូចជា ពុំទាន់បានកំណត់អំពីរចនាសម្ព័ន្ធ អង្គការលេខ នៃបណ្តាអង្គភាពក្រោមឱវាទ ទើបក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្នើសុំបំពេញបន្ថែមលើមាត្រា១១ និងមាត្រា១២ ស្តីពីការងារគ្រប់គ្រង និងរចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យ។

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាសាកលវិទ្យាល័យបណ្តុះបណ្តាល និងបម្រើវិស័យសិល្បៈវប្បធម៌ជាតិតែមួយគត់របស់ខ្មែរ មានប្រវត្តិឫសគល់កើតចេញពីថ្នាលហ្វឹកហ្វឺនអនុវត្តដោយផ្ទាល់ប្រកបដោយមូលដ្ឋានពិតៗនៃអត្តចរិក សិល្បៈវប្បធម៌ខ្មែរបរមបុរាណ តាំងពីលក្ខណៈប្រមូលផ្តុំក្នុងទម្រង់តូច មានដូចជា ចេញពីរោងជាងព្រះរាជវាំង រោងល្ខោន កកើតបានជាសាលាខេមរៈសិល្បៈនៅឆ្នាំ១៩១៧ និងក្រោយមកនៅឆ្នាំ១៩៦៥ ក៏បានវិវត្តន៍ប្រែក្លាយជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនេះឡើង។

បន្ទាប់ពីរបបប្រល័យពូជសាសន៍ប៉ុលពត អ្នកជំនាញដែលនៅមានជីវិតបានប្រមែប្រមូលគ្នាបង្កើតសាលារចនាឡើងវិញ។ ជាបន្តបន្ទាប់មកទៀតនៅឆ្នាំ១៩៨៩ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក៏បានបើកទ្វារឡើងវិញដែរ ដែលកាលដំបូងនោះ មានត្រឹមតែមហាវិទ្យាល័យបីប៉ុណ្ណោះ និងក្រោយមកក៏បានដំណើរការគ្រប់មហាវិទ្យាល័យទាំងប្រាំ គឺមហាវិទ្យាល័យបុរាណវិទ្យា មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយកម្ម

មហាវិទ្យាល័យសិល្បៈសូនរូប មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ និងមហាវិទ្យាល័យតូរ្យតន្ត្រី។ រហូតមកដល់បច្ចុប្បន្ន សាកលវិទ្យាល័យ បានបណ្តុះបណ្តាលនិស្សិតបញ្ចប់បរិញ្ញាបត្រចំនួន ១៧៥៨នាក់ ប្រកបដោយសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមអភិរក្ស និងអភិវឌ្ឍសង្គមជាតិ[១]។

អង្គប្រជុំបានពិភាក្សាគ្នាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានធ្វើការកត់សម្គាល់ផ្សេងៗគ្នា ដូចខាងក្រោមនេះ៖

+ តំណាងក្រុមប្រឹក្សាអ្នកច្បាប់បានលើកឡើងថា៖

-ទម្រង់នៃអនុក្រឹត្យមាន ៣ គឺការបង្កើត ការបំពេញបន្ថែម និងការកែសម្រួល ហើយសេចក្តីព្រាងនេះមិនមែនជាការបំពេញបន្ថែមទេ គឺការកែសម្រួលមាត្រា១១ និងមាត្រា១២ នៃអនុក្រឹត្យលេខ៥២ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្បៈជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

-បើពិនិត្យមាត្រា៨ គំនូសទី៤ នៃអនុក្រឹត្យលេខ៥២ គឺ ក្រុមប្រឹក្សាភិបាលមានសិទ្ធិគ្រប់គ្រាន់ក្នុងការរៀបចំរចនាសម្ព័ន្ធ និងស្នើតែងតាំង ដូចនេះមិនចាំបាច់មានសេចក្តីព្រាងអនុក្រឹត្យថ្មីនេះទេ ហើយម្យ៉ាងទៀតវាអាចប៉ះពាល់ដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមិនអនុញ្ញាតឲ្យមានការតែងតាំងថ្មី។

-អនុក្រឹត្យលេខ៥២ មានលក្ខណៈគ្រប់គ្រាន់អស់ហើយ មិនចាំបាច់កែសម្រួលទេ បើចង់បន្ថែមរចនាសម្ព័ន្ធសាកលវិទ្យា-ល័យភូមិន្ទវិចិត្រសិល្បៈ អាចធ្វើអនុក្រឹត្យមួយទៀតគឺ **បង្កើតផ្នែកសិក្សា និងផ្នែករដ្ឋបាល បុគ្គលិក គណនេយ្យ**

+តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានលើកឡើងថា៖

-មាត្រា៨ គំនូសទី៤ នៃអនុក្រឹត្យលេខ៥២ ក្រុមប្រឹក្សា ភិបាលមានសិទ្ធិរៀបចំរចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍសាកលវិទ្យាល័យ តែមិនអាចកំណត់ឋានុក្រមរចនាសម្ព័ន្ធថ្នាក់ស្មើនាយកដ្ឋាន ឬថ្នាក់ណាមួយទេ។ ចំណុចនេះហើយដែលយើងគួរឲ្យមានអនុក្រឹត្យកំណត់រចនាសម្ព័ន្ធឡើងវិញសម្រាប់សាលាទាំងមូល ឬ កំណត់តែផ្នែកបង្កើតថ្មីជាការចាំបាច់។ ដូចនេះ អនុក្រឹត្យលេខ ៥២ គំនូស៤ អាចខ្វះសមត្ថភាពលើចំណុចមួយចំនួន។

+តំណាងក្រសួងសាមីបានបំភ្លឺថា៖

-ក្រុមប្រឹក្សាភិបាលមានសិទ្ធិតែលើបុគ្គល ប៉ុន្តែនេះជាការរៀបចំប្រអប់រចនាសម្ព័ន្ធនិងឋានៈឲ្យទៅជាឯកសារស្របច្បាប់ និងអាចធ្វើការតែងតាំងបាន។

-បច្ចុប្បន្នសាកលវិទ្យាល័យមានរចនាសម្ព័ន្ធនិងមានការតែងតាំង ហើយនេះគឺគ្រាន់តែចង់បំពេញបន្ថែមផ្នែកសិក្សា និង ផ្នែករដ្ឋបាល បុគ្គលិក គណនេយ្យ និងឋានៈ ដើម្បីធ្វើការតែងតាំងបាន។

-ចង់ធ្វើឲ្យដូចសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានសម្រេចរួចហើយ គឺគេមានធ្វើអនុក្រឹត្យមួយកំណត់រចនាសម្ព័ន្ធសាកលវិទ្យាល័យទាំងមូលឡើងវិញ ក្រោយពេលដែលបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ជាលទ្ធផល អង្គប្រជុំបានស្នើជម្រើសពីរ៖

១-មិនចាំបាច់មានសេចក្តីព្រាងនេះទេ ព្រោះអនុក្រឹត្យ លេខ៥២ មាត្រា៨ គំនូសទី៤ មានន័យគ្រប់គ្រាន់ហើយ។

២-បង្កើតអនុក្រឹត្យស្តីពីការបង្កើតផ្នែកសិក្សា និងផ្នែករដ្ឋ បាល បុគ្គលិក គណនេយ្យ ជំនួសវិញ។

អង្គប្រជុំទី១ បានផ្អាកការពិភាក្សា៕

---

[១]អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការបំពេញបន្ថែមលើអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណរដ្ឋបាល។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន

## និងសេចក្តីព្រាងអនុក្រឹត្យស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន

កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និងឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើ **សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និង សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិអតីតយុទ្ធជន** ដោយមានការអញ្ជើញចូលរួមពីតំណាង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសេចក្តីព្រាងទាំងពីរនេះដោយឈរលើគោលការណ៍ និងសារៈសំខាន់ដូចខាងក្រោមនេះ៖

**១-គោលការណ៍រួម**

យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៤ ចែងថា " រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ "។

យោងតាមសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាអតីតយុទ្ធជន ឆ្នាំ២០០៨ ឆ្នាំ២០០៩ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេច ថ្លែងក្នុងឱកាសមហាសន្និបាតសមាគមអតីតយុទ្ធជនលើកទី១ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៧ និងក្នុងឱកាសទិវាអតីតយុទ្ធជនកម្ពុជាលើកទី២ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩។

ផ្អែកតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល មុំទី៤ ដែលចែងថា " រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការជួយឧបត្ថម្ភឲ្យបានជិតដល់ចំពោះជនពិការ និងគ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ។ ព្រមជាមួយនេះរាជរដ្ឋាភិបាលបន្តជួយគាំទ្រដល់យោធិនមន្ត្រីរាជការចូលនិវត្តន៍ តាមរយៈប្រព័ន្ធសោធននិវត្តន៍មួយ ដែលមានវិសាលភាពទូលំទូលាយ ដោយបន្តអនុវត្តបេឡាជាតិសន្តិសុខសង្គម "។



ការបង្កើតរបបសន្តិសុខសង្គម និងបេឡាជាតិសម្រាប់អតីតយុទ្ធជន ជាយុទ្ធសាស្ត្របង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និង

អនុវត្តរបបគោលនយោបាយ ដែលធានាបាននូវផលប្រយោជន៍ស្របច្បាប់របស់អតីតយុទ្ធជន ហើយឆ្លើយតបទៅនឹងគោលនយោ–បាយជាតិចំពោះវិស័យអតីតយុទ្ធជន និងព្រមទាំងដើម្បីលើកកម្ពស់ស្មារតីស្នេហាជាតិ ហ៊ានពលីកម្ម ដើម្បីបុព្វហេតុជាតិរបស់ប្រជា–ជន ជាពិសេសស្រទាប់យុវវ័យ។

២–សារៈសំខាន់

–បង្កើនប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលចំពោះអតីតយុទ្ធជន

–បង្កើនប្រសិទ្ធភាពនៃការបើកផ្តល់តាវកាលិកជូនដល់អតីតយុទ្ធជនឲ្យបានឆាប់រហ័ស និងមានតម្លាភាព

–ទប់ស្កាត់បាតុភាពអសកម្ម ការផ្ទេរ ឬការទិញលក់របប ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់អតីតយុទ្ធជន

–រួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិ ខាងវិស័យហិរញ្ញវត្ថុ

–លើកកម្ពស់ជីវភាពខាងសម្ភារៈ ស្មារតីរបស់អតីតយុទ្ធជន និងការបង្កើតបន្ថែមនូវសំណាញ់សុវត្ថិភាពសង្គម

–បង្កើតភាពជាដៃគូជាមួយវិស័យអតីតយុទ្ធជននៃបណ្តាប្រទេស និងចលនាអតីតយុទ្ធជនអន្តរជាតិ[១] ។

អង្គប្រជុំទី១ បានឯកភាពលើទស្សនៈ និងជំហរនៃសេចក្តីព្រាងទាំងពីរនេះ ហើយបានពិភាក្សាគ្នាលើខ្លឹមសារ ដោយធ្វើការកត់សម្គាល់ ដូចខាងក្រោមនេះៈ



–សេចក្តីព្រាងទាំងពីរនេះពុំមានមូលដ្ឋានច្បាប់ជាបង្អែក ដូចនេះវាមានលក្ខណៈស្វយ័ត។

–ចំណងជើងមានន័យទូលំទូលាយ ប្រហែលត្រូវកែសម្រួលឡើងវិញ។

–ខ្លឹមសាររបស់ព្រះរាជក្រឹត្យចែងច្រើនជាងច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពល–ខេមរភូមិន្ទ ដែលមានកន្លងមក។

–ស្នើកែសម្រួលព្រះរាជក្រឹត្យឲ្យបានខ្លី ជាព្រះរាជក្រឹត្យស្វយ័តសម្រាប់ចង្អុលឲ្យបង្កើតបេឡាជាតិអតីតយុទ្ធជន ដូចនេះស្នើផ្អាកការពិភាក្សា ដើម្បីទុកពេលវេលាកែសម្រួលឡើងវិញ។

ជាលទ្ធផល អង្គប្រជុំទី១ បានសម្រេចបង្កើតក្រុមការងារចង្អៀតដើម្បីរៀបចំសេចក្តីព្រាងទាំងពីរនេះឡើងវិញ។

អង្គប្រជុំទី១ បានផ្អាកការពិភាក្សា៕

[១]អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតបេឡា–ជាតិអតីតយុទ្ធជន។

### សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី

# គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ក.ស.វ.) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ដោយយោងតាមលក្ខខណ្ឌអនុកម្មវិធីទី៣ នៃចក្ខុវិស័យ និងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជ-រដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា ត្រូវធ្វើកំណែទម្រង់ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនក្នុងគោលបំណងរក្សាស្ថិរភាព នៃវិស័យហិរញ្ញវត្ថុ។

បច្ចុប្បន្ននេះ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ត្រូវបានអនុវត្តអស់រយៈពេលដប់ឆ្នាំកន្លងទៅប្រកបដោយប្រសិទ្ធភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានវិវត្តកាន់តែរឹងមាំ និងមានសុខភាពល្អឡើង។ បច្ចុប្បន្ននេះប្រព័ន្ធធនាគារនៅកម្ពុជាអាចទាក់ទាញបាននូវទំនុកចិត្តកាន់តែច្រើនឡើងពីសាធារណជន ដោយឆ្លុះបញ្ចាំងតាមរយៈការកើនឡើងអន្តរការិយកម្មធនាគារ ពោលគឺ ប្រាក់បញ្ញើបានកើនឡើងពី ៨,៨៦% នៃផលិតផលក្នុងស្រុកសរុប GDP នៅឆ្នាំ១៩៩៩ ដល់ ៣០,១២% នៅចុងឆ្នាំ២០០៩។ ឥណទានបានកើនឡើងពី ៥,៧៩% នៃផលិតផលក្នុងស្រុកសរុប GDP នៅឆ្នាំ១៩៩៩ ដល់ ២២,៨៤% នៅចុងឆ្នាំ២០០៩ និងទ្រព្យសកម្មសរុបរបស់ប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុបានកើនឡើងពី ៥៥៦,៣៤លានដុល្លារអាមេរិក ក្នុងឆ្នាំ១៩៩៩ ដល់ ៤,៨១០,៧០លានដុល្លារអាមេរិក នៅឆ្នាំ២០០៩។ ផ្នែកដែលមានការអភិវឌ្ឍលឿន និងរឹងមាំគួរឲ្យកត់សម្គាល់គឺ ធនាគារពាណិជ្ជ និង មីក្រូហិរញ្ញវត្ថុ។



វឌ្ឍភាពនៃប្រព័ន្ធធនាគារ បានឆ្លុះបញ្ចាំងតាមរយៈការចូលមកកាន់សេវាធនាគារកាន់តែច្រើនឡើងរបស់សាធារណជន។ គិតត្រឹមដំណាច់ឆ្នាំ២០០៩ នេះ សរុបចំនួនប្រជាជនដែលបានទទួលសេវាធនាគារ មានចំនួនប្រហែល ១៧% នៃប្រជាជនកម្ពុជាសរុប។ វឌ្ឍនភាពនេះក៏បានចូលរួមចំណែកផងដែរក្នុងការធ្វើឲ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងនាំឲ្យមានកំណើននៃទុនបម្រុងជារូបិយបណ្ណរបស់ប្រទេស។

បច្ចុប្បនេះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានអភិវឌ្ឍខ្លួនទាំងមូលដ្ឋានដើមទុនកាន់

តែខ្ពស់ បណ្តាញសាខាកាន់តែទូលំទូលាយនៅទូទាំងប្រទេស ការផ្តល់សេវាកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាព ដូចជាការដកប្រាក់តាមម៉ាស៊ិនទំនើប ATM សេវាធនាគារតាមទូរសព្ទនិងតាមអ៊ីនធើណេតជាដើម។ នៅពេលអនាគតដ៏ខ្លីខាងមុខ ទីផ្សារមូលបត្រនឹងចាប់ដំណើរការ ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងអាចចូលរួមយ៉ាងសកម្មនៅក្នុងទីផ្សារនេះ ដែលជាហេតុនាំឲ្យសេវាហិរញ្ញវត្ថុកាន់តែមានភាពស្មុគស្មាញឡើង។ និយាយជារួម នៅពេលដែលសេវាហិរញ្ញវត្ថុកាន់តែមានភាពទំនើបសំបូរបែប និងស្មុគស្មាញឡើង បញ្ហាសំខាន់គឺការគ្រប់គ្រងត្រួតពិនិត្យប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ឲ្យបានកាន់តែម៉ត់ចត់ឡើង ដើម្បីការពារផលប្រយោជន៍របស់អ្នកផ្ញើប្រាក់ និងឥណទាណ សំដៅដល់ការថែរក្សាឲ្យបាននូវស្ថេរភាពហិរញ្ញវត្ថុទាំងមូល ដែលកត្តាគន្លឹះនាំឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចដ៏លឿន។

ការអភិវឌ្ឍដ៏លឿននៃវិស័យហិរញ្ញវត្ថុនេះ ទាមទារឲ្យមានការអភិវឌ្ឍច្បាប់និងបទប្បញ្ញត្តិផងដែរ ដើម្បីឆ្លើយតបបាននឹងតម្រូវការឧបករណ៍ដ៏មានប្រសិទ្ធភាពដើម្បីគ្រប់គ្រងហានិភ័យ។ អាស្រ័យហេតុនេះ ទើបមានតម្រូវការឲ្យមានការធ្វើវិសោធកម្មច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរពាវត្ថុនេះឡើង។

សេចក្តីព្រាងវិសោធនកម្មនេះ រួមមានការកែប្រែខ្លឹមសារខ្លះនៅតាមមាត្រាមួយចំនួន និងបន្ថែមខ្លឹមសារមួយចំនួនទៀតឲ្យស្របតាមកាលៈទេសៈនៃការវិវត្តនៃវិស័យហិរញ្ញវត្ថុលើសកលលោក និងវិស័យហិរញ្ញវត្ថុកម្ពុជាបច្ចុប្បន្ន[១]។

អង្គប្រជុំបានឯកភាពពិនិត្យ ពិភាក្សាលើសេចក្តីព្រាងវិសោធនកម្មនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារមួយចំនួន ដើម្បីឲ្យសេចក្តីព្រាងវិសោធនកម្មនេះកាន់តែល្អប្រសើរ។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាជាបណ្តោះអាសន្ននៅមាត្រា៧ ថ្មី៕

[១]អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

## ប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ឯកឧត្តម **អ៊ុក ឆូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំឭកថា សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ឆ្លងកិច្ចប្រជុំទី១ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយជាលទ្ធផលនាពេលនោះ អង្គប្រជុំបានស្នើឲ្យក្រសួងសាមី រៀបចំខ្លឹមសារ និងកែសម្រួលរូបសញ្ញាមួយចំនួនជាថ្មីឡើងវិញ។

អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុលផុសលើសេចក្តីព្រាងកែសម្រួលថ្មីនេះ ហើយបានសម្រេចធ្វើការកែសម្រួលខ្លឹមសារ ពាក្យពេចន៍ និងរូបសញ្ញាមួយចំនួន ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អប្រសើរថែមទៀត ក៏ប៉ុន្តែនៅរក្សាទុកពាក្យមួយចំនួន ដើម្បីពិភាក្សាបន្តនៅពេលប្រជុំអន្តរក្រសួងនាពេលខាងមុខ។

អង្គប្រជុំទី១បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ៕

## ប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# លក្ខន្តិកៈរបស់សាស្ត្រាចារ្យសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល



កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាពឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ) និងឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពី លក្ខន្តិកៈរបស់សាស្ត្រាចារ្យសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសុខាភិបាល សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំឭកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខន្តិកៈរបស់សាស្ត្រាចារ្យសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល បានដាក់ឆ្លងកិច្ចប្រជុំទី១ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ ហើយជាលទ្ធផលនាពេលនោះគឺ បង្កើតក្រុមការងារមួយដើម្បីរៀបចំកែសម្រួលតាមស្មារតីរបស់អង្គប្រជុំ។

អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុលផុសលើសេចក្តីព្រាងកែសម្រួលថ្មីនេះ ដោយសម្រេចកែសម្រួលចំណងជើងទៅជា " អនុក្រឹត្យស្តីពីការកំណត់ឋានៈបណ្ឌិតសភារបស់សាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល " វិញ ព្រោះថា អនុក្រឹត្យនេះខ្លី មានតែ ១៨មាត្រា ដូចនេះមិនគួរប្រើពាក្យ " លក្ខន្តិកៈ " ទេ លក្ខន្តិកៈត្រូវមានខ្លឹមសារ និងមាត្រាច្រើនជាងនេះ។ ពាក្យ " សាស្ត្រាចារ្យ " មិនមែនជាមុខតំណែងឋានៈតួនាទីក្នុងរដ្ឋបាល ឬភារកិច្ចដែលគេប្រគល់ឲ្យទេ។ វាជាងារមួយ (titre scientifique) ដែលគេវាយតម្លៃទទួលស្គាល់ តាមការប្រឡងជ្រើសរើសអ្នកមានសមត្ថភាពខាងបង្រៀននិងស្រាវជ្រាវក្នុងវិស័យសុខាភិបាល។ ហេតុនេះហើយទើបអង្គប្រជុំសម្រេចប្រើពាក្យ " ឋានៈបណ្ឌិត្យសភា " ក្នុងចំណងជើង។ ក្រៅពីនេះអង្គប្រជុំបានសម្រេចកែសម្រួលខ្លឹមសារ និងទម្រង់ខ្លះទៀត ដើម្បីឲ្យសេចក្តីព្រាងនេះកាន់តែសុក្រឹត្យ។

សព្វថ្ងៃនៅតាមគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ (សាធារណៈ និងឯកជន) អ្នកបង្រៀនជាច្រើនប្រើពាក្យ "សាស្ត្រាចារ្យ " សម្រាប់សម្គាល់ភារកិច្ចអ្នកបង្រៀន ដោយពុំមានលិខិតគតិយុត្តណាមួយកំណត់ជាផ្លូវការឡើយ។

ពេលអនុក្រឹត្យរបស់ក្រសួងសុខាភិបាលនេះចេញ ក្រសួងឯទៀតដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចនឹងរៀបចំអនុក្រឹត្យនេះសម្រាប់គ្រឹះស្ថានឧត្តមសិក្សារបស់ខ្លួន។ ការរៀបចំដោយឡែកៗនៅពេលក្រោយមកនេះ នឹងជួបការលំបាកព្រោះក្រសួងនីមួយៗមិនទាន់មានការតែងតាំងសាស្ត្រាចារ្យជាករណីពិសេស (ក្រសួងសុខាភិបាលបានតែងតាំងសាស្ត្រាចារ្យមហាបរិញ្ញាប្រមាណ ៥០នាក់ ដោយព្រះរាជក្រឹត្យ និងប្រកាស)។

ដើម្បីឲ្យឯកភាពគ្នា និងចៀសវាងការខុសឆ្គងក្នុងការផ្តល់ឋានៈបណ្ឌិត្យសភានៅទូទាំងប្រទេស គប្បីមានព្រះរាជក្រឹត្យ ឬអនុក្រឹត្យរួមមួយសម្រាប់គ្រប់ក្រសួង។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះ៕

## ប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី

# ការត្រួតពិនិត្យគ្រឿងញៀន

កាលពីថ្ងៃទី០២, ០៣, ០៨, ០៩, ១៥ និងទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាពឯកឧត្តម **ប៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និងឯកឧត្តម **អ៊ុក ឡូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើសេចក្តីព្រាងច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ដោយមានការអញ្ជើញចូលរួមពីតំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



រយៈពេល ០៦ថ្ងៃនេះ អង្គប្រជុំបានបន្តពិនិត្យពិភាក្សាគ្នាយ៉ាងផុលផុស និងយកចិត្តទុកដាក់លើសេចក្តីព្រាងច្បាប់នេះ ចាប់ពីជំពូកទី១ រហូតដល់ជំពូកទី៦ មាត្រា៤៩ ហើយបានសម្រេចធ្វើការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួនដើម្បីធ្វើឲ្យសេចក្តីព្រាងច្បាប់នេះ កាន់តែល្អប្រសើរ។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាជាបណ្តោះអាសន្ននៅត្រឹមជំពូកទី៦ មាត្រា៤៩។



# ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ក្នុងពិធីសម្ពោធ " កន្លែងលក់ថ្មីរបស់ក្រុមហ៊ុនចំរុះសិប្បករអង្គរ " នៅរាជធានីភ្នំពេញ

ថ្ងៃសុក្រ ទី២២ ខែមករា ឆ្នាំ២០១០

ក្នុងឱកាសនោះ ឯកឧត្តម **យឹម ណុលឡា** មានប្រសាសន៍ថា " ជាការពិតណាស់ អាជីវកម្មរបស់ក្រុមហ៊ុនចំរុះសិប្បករអង្គរ ទទួលបាននូវការចាប់អារម្មណ៍ និងគាំទ្រពីសំណាក់ ឯកឧត្តមបណ្ឌិត **សុខ អាន** ពីព្រោះជាប្រភេទអាជីវកម្មដែលចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការអភិរក្សបេតិកភណ្ឌអង្គរ ជាពិសេសការបង្កើតសកម្មភាព នៃការងារហត្ថកម្ម និងសកម្មភាពដែលមានអត្ថន័យសំរាប់សង្គមជាតិ និងការការពារ និងរិក្រឹតការលើមុខរបរដែលមានតាំងពីសម័យអង្គរ។





គំរោងសិប្បករអង្គរ ត្រូវបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៨៧ ដែលជាគំនិតផ្តួចផ្តើមរបស់ភាគីកម្ពុជា និងភាគីបារាំង។ ភាគីបារាំងមានលោក Maisonnave និងភាគីកម្ពុជាមានលោក **តោ គិមស៊ាន** ដែលពេលនោះលោកមាននាទីជាប្រធានមន្ទីរអប់រំខេត្តសៀមរាប (លោកក៏មានវត្តមានជាមួយយើងក្នុងរាត្រីនេះផងដែរ)។ គំរោងនេះ គឺមានគោលបំណងស្វែងរកការងារសំរាប់យុវជនក្រីក្ររស់នៅតាមជនបទ។ បន្ទាប់មកការដ្ឋានសាលាមួយត្រូវបានបង្កើតឡើងនៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៩២ ដែលទទួលបានជំនួយដំបូងពីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) (ខ្ញុំសូមស្វាគមន៍ផងដែរចំពោះតំណាងរបស់ AFD ដែលមានវត្តមាននៅទីនេះ)។ បន្ទាប់មកកម្មវិធីរេផ្លិក (REPLIC) របស់សហគមន៍អឺរ៉ុបបានជួយជាបន្ត ដោយផ្តល់លទ្ធភាពអភិវឌ្ឍន៍ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០១ លើដំណើការបណ្តុះបណ្តាលមុខរបរ សូត្រ និង ឌុកម្រ័ក្ស ក្រោមការជំរុញរបស់ប្រធានទី១ របស់សិប្បករអង្គរ គឺលោក Jean Pierre Martial។ នៅឆ្នាំ១៩៩៩ សកម្មភាពពាណិជ្ជកម្ម

បានចាប់ដំណើរការយ៉ាងពិតប្រាកដ។ ការកើនឡើងនៃភ្ញៀវទេសចរណ៍ដែលមកទស្សនាតំបន់អង្គរបាននាំមកនូវការរីកចំរើនយ៉ាងលឿន នៅក្នុងផ្នែកពាណិជ្ជកម្មផលិតផល។

នៅខែឧសភា ឆ្នាំ២០០០ សមាគមសិប្បករអង្គរ ដែលប្រមូលផ្តុំសិប្បករនិយោជិត ត្រូវបានបង្កើតឡើង នឹងត្រូវបានសម្ពោធជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា។ សមាគមនេះមានគោលបំណងជួយសិប្បករនិយោជិតលើផ្នែកសង្គម និងសេដ្ឋកិច្ច និងមានចំណែកមួយនៃភាគហ៊ុនរបស់ក្រុមហ៊ុនសិប្បករអង្គរ។



ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនិងការរីកចំរើននៃវិស័យទេសចរណ៍ និងសិប្បករអង្គរ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០០៣ ក្រុមហ៊ុនចំរុះសិប្បករអង្គរត្រូវបានបង្កើតឡើង ដែលជាសមិទ្ធិផលពិសេសមួយនៃការចងសម្ព័ន្ធគ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយម្ចាស់ភាគហ៊ុនឯកជន និងសហការីរបស់ក្រុមហ៊ុន។ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជម្រុញការវិនិយោគរបស់វិស័យឯកជន និងតាមការស្នើរបស់អាជ្ញាធរកម្ពុជា ក្រុមហ៊ុន VINCI តាមរយៈសាខារបស់ខ្លួនគឺក្រុមហ៊ុន SCA នៅឆ្នាំ ២០០៥ បានចូលរួមក្នុងភាគហ៊ុនរបស់ក្រុមហ៊ុន ហើយបានធ្វើអោយស្ថានភាពក្រុមហ៊ុនសិប្បករអង្គរមានស្ថេរភាព។ ចាប់តាំងពីពេលនោះមកម្ចាស់ភាគហ៊ុនទាំង រដ្ឋាភិបាល និងឯកជន បានទទួលលទ្ធផលគួរជាទីចាប់អារម្មណ៍ជាបន្តបន្ទាប់ និងរីកចំរើនប្រកបដោយទស្សនៈផ្សារភ្ជាប់ជាមួយប្រជាជន និងប្រទេសកម្ពុជា។

ក្នុងឋានៈទូលបង្គំ ខ្ញុំជាសមាជិករាជរដ្ឋាភិបាលមួយរូប ខ្ញុំអាចនិយាយបានថា រាជរដ្ឋាភិបាលកម្ពុជា មានមោទនភាពដែលមានក្រុមហ៊ុនចំរុះមួយបានចូលរួមដោយផ្ទាល់ក្នុងការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រដោយផ្ទាល់ ក្នុងនោះរួមមាន៖

១-ទទួលភ្ញៀវទេសចរណ៍ជាង ៣៥០០០០ នាក់ក្នុង ០១ឆ្នាំ

២-ទ្រទ្រង់ជីវភាពដល់ប្រជាជនជិត ៥០០០ គ្រួសារ តាមរយៈការផ្ដល់ការងារ

៣-ចូលរួមចំណែកក្នុងការបណ្ដុះបណ្ដាលយុវជនក្រីក្ររស់នៅតាមជនបទ ដែលជាមធ្យមក្នុងមួយឆ្នាំ សិប្បករចំនួនជាង ១០០នាក់ បានទទួលការបណ្ដុះបណ្ដាល និងផ្ដល់អោយពួកគេនូវវិជ្ជាជីវៈមួយយ៉ាងពិតប្រាកដ ដោយគោរពនូវកេរ្ដិ៍តំណែលរបស់ជាតិខ្មែរយើង



៤-ស្វ័យហិរញ្ញប្បទានទាំងស្រុង និងរៀបចំវិនិយោគបន្ត ដើម្បីឆ្លើយតបនឹងកំណើននៃសេដ្ឋ-កិច្ចនាពេលខាងមុខ

៥-ត្រូវបានចាត់ទុកជាក្រុមហ៊ុនដែលបានបង្កើតការងារ បង់ពន្ធ និងនាំចេញផលិតផលទៅបរទេស។

តាងនាមទីស្ដីការគណៈរដ្ឋមន្ត្រី ខ្ញុំសូមកោតសរសើរចំពោះកំរិតគុណភាព និងការកែឆ្នៃជាថ្មីដ៏ល្អវិចិត្ររបស់សិប្បករអង្គរ ដោយចេះរក្សាលក្ខណៈដើម និងលក្ខណៈសង្គមនៃគំរោងដ៏ល្អរបស់ខ្លួនសំរាប់យើងទាំងអស់គ្នា និងនិយោជិត សហាការីទាំង ១១០០នាក់របស់ក្រុមហ៊ុន។



តាមលទ្ធផលខាងលើក្រុមហ៊ុនចំរុះសិប្បករអង្គរ បានចូលរួមដោយផ្ទាល់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជាដោយផ្ទាល់ ស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខដឹកនាំដ៏ខ្ពង់ខ្ពស់ " ៕

# ទស្សនៈកិច្ចសិក្សាស្តីពី ការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត (RIA) នៅប្រទេសអូស្ត្រាលី



ដោយបានទទួលការអនុញ្ញាពីឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ក.ស.វ. / ECOSOCC ឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធាន ក.ស.វ. / ECOSOCC បានដឹកនាំគណៈប្រតិភូ ក.ស.វ. / ECOSOCC រួមមាន ឯកឧត្តម **យឹម ឈុលសន** ឯកឧត្តម **ទេវ សំអាង** និងឯកឧត្តម **ហុង ជឿន** ធ្វើទស្សនៈកិច្ចសិក្សាដកបទពិសោធស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅប្រទេសអូស្ត្រាលី រយៈពេល ០៥ថ្ងៃ ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៥ ខែកុម្ភៈ ២០១០ ដែលរៀបចំ និងឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១០ គណៈប្រតិភូបានធ្វើទស្សនៈកិច្ចសិក្សានៅ :

១- Queensland Office for Regulation Efficiency (QORC) ដោយបានជួបសន្ទនាជាមួយលោក Peter Mckenna, Director, QORE លោក Eleanor Mak, Manager និងលោក Daniel Cahill។

២- i-Lab – Queensland Technology Incubator

៣- Meeting with the Parliamentarians ដោយបានជួបសន្ទនាជាមួយលោកស្រី Jan Jarratt, Parliamentary Secretary (Junior minister) for Employment and Economic Development លោក Evan Moorehead, Parliamentarian និងលោក Lyndel Bates, Acting Research Director។



ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០ គណៈប្រតិភូបានធ្វើទស្សនៈកិច្ចសិក្សានៅ :

៥- Deregulation Group, Department of Finance and Deregulation, Canberra ដោយបានជួបសន្ទនាជាមួយលោកស្រី Susan Page, Deputy Secretary, Deregulation Group, Chaired the session, Head of the OBPR និងលោកប្រធាន Deregulation Plicy Division។

៦- Office of Best Practice Regulation (OBPR), Canberra ដោយបានជួបសន្ទនាជាមួយ លោក Darrell Porter, Deputy Executive Director។

ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០ គណៈប្រតិភូបានធ្វើទស្សនៈកិច្ចសិក្សានៅ :

៧- Minister of Finance and Deregulation, Canberra ដោយបានជួបសន្ទនាជាមួយ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ លោក Hon Lindsey Tanner, Senior minister in the Australian Cabinet។

៨- Productivity Commission ដោយបានជួបសន្ទនាជាមួយ លោក Terry O'Brien, Firt Assistant Commisioner និងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀតដែលពាក់ព័ន្ធនឹងការងារបញ្ញត្តកម្ម។

៩- Food Standards Australia New Zealand (FSANZ) ដោយបានជួបសន្ទនាជាមួយ លោកស្រី Melanie Fisher, General Manager, Food Standards Branch លោក Jason March និងលោក Rishi Khandelwal។

ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០ គណៈប្រតិភូបានធ្វើទស្សនៈកិច្ចសិក្សានៅ :

១០- Environment Protection Agency (EPA),Melbourne, Victoria ដោយបានជួបសន្ទនាជាមួយ លោក Wayne Robins, Director, Client service និងលោក Kylie Brown, Economic Policy Office, Regulation Innovation Unit។

១១- Australian Competion and Consumer Commision (ACCC) ដោយបានជួបសន្ទនាជាមួយ លោក Joe Dimasi, Commissioner លោកស្រី Anne Plympton, General Manager, Regulation Development និងលោក Daryl Biggar, Regulation Economic Adviser។

ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ គណៈប្រតិភូបានធ្វើទស្សនៈកិច្ចសិក្សានៅ :

១២- Victorian Competition and Efficiency Commission (VCEC), Melbourne ដោយបានជួបសន្ទនាជាមួយ លោក Matthew Butlin, Commisioner លោក Richard Clarke, Executive Director និងលោក Sam Abusah, Assistant Director។

១៣- Department of Premier and Cabinet (DPC), Victoria ដោយបានជួបសន្ទនាជាមួយ លោក Simon Corden, Chief Economic Policy Adviser។

១៤- Department of Treasury and Finance, Victoria ដោយបានជួបសន្ទនាជាមួយ លោក Vin Martin, Director លោក Jarrod Ball elak Sanjeev Sablock។



ក្នុងរយៈពេល ០៥ថ្ងៃនេះ គណៈប្រតិភូបានទស្សនៈកិច្ចសិក្សាចំនួន ១៤កន្លែង ហើយបានយល់ដឹងអំពីអត្ថប្រយោជន៍នៃការធ្វើកំណែទម្រង់លិខិតបទដ្ឋានគតិយុត្តដើម្បីកំណើនសេដ្ឋកិច្ច ដែលជាការងារលំបាកទាមទារការប្រឹងប្រែងការគាំទ្រពីថ្នាក់នយោបាយជាន់ខ្ពស់ ការគាំទ្រពីថ្នាក់ការិយាល័យ ការពិគ្រោះយោបល់ កម្លាភាព សមត្ថភាពជំនាញ ការលើកទឹកចិត្ត និងការចាប់ផ្តើមអនុវត្តដោយសន្សឹមៗទើបទទួលបានជោគជ័យ។

# សកម្មភាពផ្សេងៗរបស់ឯកឧត្តម យឹម ឈុនឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កុម្ភៈ ឆ្នាំ ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១.០២.១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធិផលនានា ក្នុងវត្តចំពុះក្អែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ។ |
| ២ | ០២.០២.១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីធ្វើសមយុទ្ធគ្រប់គ្រងគ្រោះអាសន្នទ្រង់ទ្រាយធំនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅមូលដ្ឋានកងទ័ពជើងអាកាស។ |
| ៣ | ០៨.០២.១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខារវាង Universite de Palerme ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងអជ្ញាធរអប្សរា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៨, ០៩, ១៩. ០២.១០ ព្រឹក | ប្រជុំគណៈកម្មការដេញថ្លៃ និងត្រួតពិនិត្យការសាងសង់អគារវាយនភ័ណ្ឌប្រពៃណីអាស៊ាន នៅក្រុងសៀមរាបអង្គរ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៥.០២.១០ ល្ងាច | ប្រជុំជាមួយឯកឧត្តម **ង៉ោ ហុងលី** ស្ដីពីការសាងសង់ទីស្នាក់ការអាជ្ញាធរអប្សរាក្រុងសៀមរាប នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៧.០២.១០ ល្ងាច | ចូលរួមប្រជុំជាមួយ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីការសាងសង់ទីស្នាក់ការអាជ្ញាធរអប្សរាក្រុងសៀមរាប នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១៨.០២.១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីបើកមហាស្រពសិល្បៈល្ខោននាដខ្មែរទូទាំងប្រទេស ដើម្បីអបអរសាទរទិវាវប្បធម៌ជាតិ ០៣ មីនា ឆ្នាំ ២០១០ (លើកទី ១២) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ១៩.០២.១០ ព្រឹក | ចូលរួមក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។<br>២-សេចក្តីព្រាងច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។<br>៣-បញ្ហាផ្សេងៗ |
| ៩ | ២២.០២.១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីថ្វាយព្រហារាជដំណើរដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យស្តេចនឹងយាងទៅទីក្រុងបេកាំងនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីក្រាបបង្គំគាល់សួរសុខទុក្ខ **ព្រះករុណាព្រះវររាជបិតាជាតិខ្មែរ និងសម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងយាងពិនិត្យព្រះរាជសុខភាពតាមព្រះទីនាំងយន្តហោះពិសេស។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម គីម សយសាម៉ាឡែន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កុម្ភៈ ឆ្នាំ ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១-០៦.០២.១០ | ទស្សនកិច្ចសិក្សានៅប្រទេសអូស្ត្រាលីស្តីពី ការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត។ |
| ២ | ០៨.០២.១០ | ប្រជុំជាមួយឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីច្បាប់នីតិវិធីបណ្តឹងពាក់ព័ន្ធនឹងឋានៈបុគ្គល។ |
| ៣ | ០៨.០២.១០ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខារវាង Universite de Palerme ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងអង្គាធរអប្សរា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១០.០២.១០ | ប្រជុំជាមួយ Inception Mission របស់ ADB សម្រាប់ Promoting Economic Diversification Program។ |
| ៥ | ១៨.០២.១០ | ចូលរួមជាកិត្តិយសក្នុងពិធីបើកមហាស្រពសិល្បៈល្ខោននាដខ្មែរទូទាំងប្រទេស ដើម្បីអបអរសាទរទិវាវប្បធម៌ជាតិ ០៣ មីនា ឆ្នាំ ២០១០ (លើកទី ១២) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |
| ៦ | ២៣-២៥.០២.១០ | ចូលរួមទស្សនកិច្ចពិភាក្សា Senior Executive Retreat: Enhancing Regulatory Duality for Economic Growth នៅក្រុងសៀមរាប។ |

# ព្រឹត្តិបត្រព័ត៌មាន


នាយកគ្រប់គ្រងទូទៅ : ឯកឧត្តម គីម សយសាម៉ាឡែន អនុប្រធាន ក.ស.វ.

និពន្ធនាយក : ឯកឧត្តម មឌ្យ សំអាង អគ្គលេខាធិការ ក.ស.វ.

និពន្ធអគ្គបទ : ឯកឧត្តម អេង វត្តមុនី អគ្គលេខាធិការរង ក.ស.វ.

បច្ចេកទេសកុំព្យូទ័រ និងចាត់ចែងទូទៅ : លោក សយ ថាស្លា ប្រធានការិយាល័យ ក.ស.វ.

យកព័ត៌មាន និងថតរូប : លោក ហេង សុគះបញ្ញា ប្រធានការិយាល័យ ក.ស.វ.

ទំនាក់ទំនង និងបោះពុម្ពផ្សាយ : លោក ម៉ក់ ឆារ៉ា ជំនួយការទេសរដ្ឋមន្ត្រី ប្រធាន ក.ស.វ.




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasnaarrow@gmail.com